# ផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចសាកល លើភាពក្រីក្រ និងការអភិវឌ្ឍសង្គមនៅកម្ពុជា[1]

## ប្រវត្តិព្រឹត្តិការណ៍

វិបត្តិហិរញ្ញវត្ថុសាកល បានលេចឡើងកាន់តែច្បាស់ក្នុងអំឡុងខែកញ្ញា ២០០៨ ដោយសារការដួលរលំបណ្តាស្ថាប័នហិរញ្ញវត្ថុធំៗជាច្រើន ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក ។ វិបត្តិនេះ បានរីករាលដាលចេញពីសហរដ្ឋអាមេរិក ទៅកាន់ប្រទេសផ្សេងៗទៀតក្នុងទូទាំងសាកលលោក រួមទាំងប្រទេសកំពុងអភិវឌ្ឍន៍ ដូចជា ប្រទេសកម្ពុជាជាដើម ។

ដោយទទួលបានជំនួយទ្រទ្រង់ជាហិរញ្ញវត្ថុ និងបច្ចេកទេសពីវិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស (Overseas Development Institute) និងធនាគារពិភពលោក វិទ្យាស្ថាន CDRI បានធ្វើការសិក្សា និងវាយតម្លៃលើផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកលនៅកម្រិតម៉ាក្រូ (Jalilian *et al*. 2009) នៅតាមវិស័យនីមួយៗ (កសិកម្ម កាត់ដេរ ទេសចរណ៍ និងសំណង់) (Jalilian *et al*. 2009) នៅកម្រិតគ្រួសារ (Tong *et al*. forthcoming) និងកម្រិតបុគ្គល (Tong *et al*. 2009) ។ អត្ថបទនេះ បង្ហាញពីរបកគំហើញសំខាន់ៗ និងពិនិត្យមើលលើការឆ្លើយតបមួយចំនួនក្នុងពេលកន្លងមករបស់វិស័យសាធារណៈ ។

> **ភាពក្រីក្រមានភាគច្រើននៅជនបទ ដូច្នេះ គេគួរពិនិត្យជាសំខាន់ពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកល ទៅលើសេដ្ឋកិច្ច និងកសិកម្មនៅជនបទ ។**

មានការទទួលស្គាល់ជាទូទៅថា សេដ្ឋកិច្ចកម្ពុជា បានទទួលរងឥទ្ធិពលធ្ងន់ធ្ងរពីវិបត្តិហិរញ្ញវត្ថុសាកល ជាពិសេសដោយសារការរួមចុះក្នុងវិស័យកាត់ដេរ ទេសចរណ៍ និង សំណង់ ។ នៅកម្ពុជា វិបត្តិនេះ ប៉ះពាល់ធ្ងន់ធ្ងរជាងគេដល់ឧស្សាហកម្មកាត់ដេរ ដោយក្នុងចំណោមកម្មករសរុប ៣៥២.០០០នាក់ មាន ១៨% (ភាគច្រើនជានារី) បានបាត់បង់ការងារ នៅចន្លោះខែកញ្ញា ២០០៨ និងខែឧសភា ២០០៩ ដោយសារការនាំចេញធ្លាក់ចុះខ្លាំង ។ យោងតាមវិទ្យាស្ថានជាតិស្ថិតិ វិស័យកាត់ដេរ ផ្តល់ការងារដល់ប្រមាណ ៤% នៃកំលាំងពលកម្មសរុប និងមានចំណែក ៣៨% ក្នុងការងារផ្នែកកម្មន្តសាលសរុប នៅឆ្នាំ២០០៧ ។

នៅឆមាសទី១ ឆ្នាំ២០០៩ ភ្ញៀវទេសចរមកដល់កម្ពុជា មានសរុប ១.០៨៦.៥១៨នាក់ គឺប្រហាក់ប្រហែលនឹងតួលេខនៅឆមាសទី១ ឆ្នាំ២០០៨ និងមានកំណើនប្រមាណ ១២% ពីខែមករា-មិថុនា ២០០៧ ។ ប៉ុន្តែវិស័យទេសចរណ៍ បានរួមចុះជាមធ្យមអស់ ៣,៩%ក្នុងមួយខែក្នុងរយៈពេល ៦ខែជាប់ៗគ្នា ពីខែតុលា ២០០៨ ដល់មីនា ២០០៩ ។ ជាលទ្ធផល អត្រាស្នាក់នៅតាមសណ្ឋាគារជាច្រើន មានកម្រិតទាប ដែលធ្វើឱ្យសណ្ឋាគារប្រណីតមួយចំនួន ត្រូវផ្អាកដំណើរការជាបណ្តោះអាសន្ន ហើយបុគ្គលិកសណ្ឋាគារ ក៏ត្រូវឈប់សំរាកដោយគ្មានបៀវត្សរ៍ ឬក៏បញ្ឈប់ជាបណ្តោះអាសន្នពីការងារ ។

ក្នុងពេលជាមួយគ្នា សកម្មភាពសំណង់ ក៏ត្រូវធ្លាក់ចុះជាខ្លាំងដែរ ដោយសារវិនិយោគិនបរទេសក្នុងវិស័យអចលនទ្រព្យ គេកាត់បន្ថយទំហំគម្រោង ឬពន្យារពេលគម្រោងសាងសង់ធំៗ ដោយសារវិបត្តិឥណទាននៅក្នុងប្រទេសដើមរបស់ពួកគេ ។

## ផលប៉ះពាល់នៃវិបត្តិទៅលើភាពក្រីក្រ

អត្រាប៉ាន់ស្មាននៃប្រជាជនក្រីក្រនៅឆ្នាំ២០០៧ គឺ ៣៥% នៅតំបន់ជនបទ ធៀបនឹង ០,៨% នៅរាជធានីភ្នំពេញ និង ២២% នៅក្រុងដទៃទៀត (World Bank 2009) ។ នៅឆ្នាំ២០០៧ ខ្សែបន្ទាត់ភាពក្រីក្រជារួមនៅតំបន់ជនបទកម្ពុជា មានកម្រិតស្មើនឹង ០,៥៨ដុល្លារ (World Bank 2009) ។ ផ្អែកលើខ្សែបន្ទាត់ភាពក្រីក្រអន្តរជាតិ ដែលមានអំណាចទិញស្មើគ្នា ក្នុងចំណោម ប្រជាជនកម្ពុជាសរុប ១៣,៨លាននាក់ មាន ៤០,២% រកចំណូលបានក្រោម ១,២៥ដុល្លារ/ថ្ងៃ ហើយ ៦៨,២% មានចំណូលក្រោម ២ដុល្លារ/ថ្ងៃ នៅឆ្នាំ២០០៤ (Bauer *et al*. 2008) ។ ដោយហេតុថា នៅកម្ពុជា ភាពក្រីក្រមានភាគច្រើននៅតំបន់ជនបទ ដែលមានកសិកម្មជាសកម្មភាពសេដ្ឋកិច្ចចំបង ដូច្នេះ គេគួរពិនិត្យជាសំខាន់ពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកលទៅលើសេដ្ឋកិច្ច និងកសិកម្មនៅជនបទ ។

កសិកម្ម រួមចំណែកប្រហែល ២៧% នៃ ផសស នៅឆ្នាំ២០០៧ ហើយប្រជាជន ៥៩% ពឹងផ្អែកលើវិស័យនេះ ដើម្បីដោះស្រាយជីវភាពរស់នៅ ។ ក្នុងមួយទសវត្សរ៍កន្លងមក វិស័យកសិកម្មបានរីកលូតលាស់តាមអត្រាប្រចាំឆ្នាំ ៤,៦% ធៀបនឹង ១៣,១% សម្រាប់វិស័យសណ្ឋាគារ និងភោជនីយដ្ឋាន (សូចនាករតំណាងសម្រាប់វិស័យទេសចរណ៍) ២៥,៤%សម្រាប់ផ្នែកវាយនភ័ណ្ឌ សំលៀកបំពាក់ និងទ្រនាប់ជើង (សូចនាករតំណាងសម្រាប់វិស័យកាត់ដេរ) ១៣,៩% សម្រាប់វិស័យសំណង់ និង ៩,១% សម្រាប់សេដ្ឋកិច្ចទាំងមូល ។ គេរំពឹងថា វិស័យកសិកម្ម នឹងមានកំណើនខ្លាំងនៅឆ្នាំនេះ ហើយជួយប៉ះប៉ូវដល់ការធ្លាក់ចុះក្នុងវិស័យផ្សេងៗទៀត ពីព្រោះកសិកម្ម ទំនងជាមិនសូវប៉ះពាល់ខ្លាំងដោយសារវិបត្តិសេដ្ឋកិច្ចសាកលឡើយ (Jalilian *et al*. 2009) ។

ដើម្បីវាយតម្លៃពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកលលើគ្រួសារនៅកម្ពុជា កាលពីខែឧសភា ២០០៩ វិទ្យាស្ថាន CDRI បានសហការជាមួយ

---

១ អត្ថបទសង្ខេបគោលនយោបាយនេះ លោក តុង គឹមស៊ុន ជាអ្នកសំរបសំរួលកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៅ CDRI បានរៀបចំឡើងសម្រាប់សន្និសីទតំបន់អាស៊ី ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី ២៨-២៩ កញ្ញា ២០០៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម ។

ក្រាហ្វិក ១ : ខ្សែកោងនៃអត្រាភាពក្រីក្រសម្រាប់ខែមីនា ២០០៨ និង ឧសភា ២០០៩




*ប្រភព: អង្កេតរបស់ CDRI លើក្រុមគ្រួសារចំនួន ៩០ នៅក្នុងភូមិចំនួន ៩ រវាងខែមីនា ២០០៨ និង ឧសភា ២០០៩ ។*

ធនាគារពិភពលោក ដើម្បីធ្វើអង្កេតជាក្រុមលើប្រជាជនចំនួន ៩០គ្រួសារ នៅតំបន់ដែលបានធ្វើការសិក្សាពីឌីណាមិកនៃភាពក្រីក្រ ។ ទិន្នន័យដែលប្រមូលបានពី ៩ភូមិក្នុង ៧ខេត្ត កាលពីខែមីនា ២០០៨ និងខែឧសភា ២០០៩ បង្ហាញថា ចំណូល និងចំណាយក្នុងមនុស្សម្នាក់ បានធ្លាក់ចុះខ្លាំងក្នុងអំឡុងពេលនោះ ពោលគឺចំណូល បានធ្លាក់ចុះ ៣០% និងចំណាយ ធ្លាក់ចុះ ២៣% ។ ទំហំដីកសិកម្ម និងដីលំនៅដ្ឋាន មិនមានការប្រែប្រួលខ្លាំងទេ ប៉ុន្តែតម្លៃនៃទ្រព្យសកម្មក្រៅពីដីធ្លី បានធ្លាក់ចុះអស់ ៣៨% ទ្រព្យប្រើប្រាស់បានយូរ ធ្លាក់ចុះ ៣០% ហើយសត្វចិញ្ចឹម ធ្លាក់ចុះ ៤៥% ។ ជាលទ្ធផល នៅឆ្នាំ២០០៩ អត្រាភាពក្រីក្រ បានកើនឡើង ដោយកំណត់តាមខ្សែបន្ទាត់ភាពក្រីក្រស្មើនឹង ១ដុល្លារ[២] (ក្រាហ្វិក ១)[៣] ។

អង្កេតលើចំណូលប្រចាំថ្ងៃរបស់ពលករងាយរងគ្រោះ នៅរាជធានីភ្នំពេញ និងខេត្តពីរផ្សេងទៀត ដែល CDRI បានធ្វើជាច្រើនឆ្នាំមកហើយ បង្ហាញថា វិបត្តិហិរញ្ញវត្ថុសាកល បានប៉ះពាល់កម្មកររោងចក្រកាត់ដេរធ្ងន់ធ្ងរជាងគេ ព្រោះវិស័យកាត់ដេរពឹងផ្អែកខ្លាំងលើតំរូវការពីសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប[៤] ។ ចំណូលប្រចាំថ្ងៃពិតរបស់កម្មកររោងចក្រកាត់ដេរ បានធ្លាក់ចុះប្រហែល ១៧% បើធៀបកម្រិតកាលពីខែកុម្ភៈ-ឧសភា ២០០៧ និងកម្រិតខែកុម្ភៈ-ឧសភា ២០០៩ ដែលឆ្លុះបញ្ចាំងពីអត្រាប្រាក់កំរៃការងារថេរ ការកាត់បន្ថយចំនួនម៉ោងធ្វើការ និងអត្រាអតិផរណាខ្ពស់ ។ ទោះបីប្រាក់ចំណូលធ្លាក់ចុះក្តី ចំណាយប្រចាំថ្ងៃពិត បានកើនឡើង ១៤% ដែលអាចមកពីកំហុសក្នុងការវាស់វែង ឬការជ្រើសយកគំរូតាង ។ ក្នុងពេលដំណាលគ្នា ប្រាក់សន្សំប្រចាំថ្ងៃពិត បានធ្លាក់ចុះ ២១% ។ ប្រាកដណាស់ ចំណាយប្រចាំថ្ងៃរបស់កម្មកររោងចក្រកាត់ដេរ មិនអាចនៅថេរឡើយ ប្រសិនបើចំណូល និងប្រាក់សន្សំប្រចាំថ្ងៃរបស់ពួកគេ បន្តធ្លាក់ចុះនោះ ។

អង្កេតបានបង្ហាញផងដែរថា ចំនួនចារិកនៃប្រាក់ផ្ញើមកផ្ទះប្រចាំខែជាមធ្យមរបស់កម្មកររោងចក្រកាត់ដេរ បានធ្លាក់ចុះ ៣២% ពី ២៤,៤០ដុល្លារ នៅខែកុម្ភៈ មកត្រឹម ១៨,៤០ដុល្លារនៅខែឧសភា ២០០៩ ។ ការធ្លាក់ចុះគួរឱ្យកត់សំគាល់នៃប្រាក់ផ្ញើមកផ្ទះនេះ បានដាក់សម្ពាធធ្ងន់ធ្ងរលើជីវភាពរស់នៅរបស់សាច់ញាតិពួកគេ ។

វិបត្តិហិរញ្ញវត្ថុសាកល បានប៉ះពាល់លើកម្មករ ៩ក្រុមទៀត តិចជាងកម្មកររោងចក្រកាត់ដេរ ។ គួរកត់សំគាល់ដែរថា អង្កេតនេះ បានជ្រើសយកតែពលករដែលមានការងារធ្វើ ឬប្រកបអាជីវកម្មដោយខ្លួនឯង ដូច្នេះលទ្ធផលអង្កេត មិនអាចឆ្លុះបញ្ចាំងពីស្ថានភាពរបស់ពលករជាទូទៅបានទេ ។

ការពិភាក្សាតាមក្រុមស្នូល ដែលធ្វើឡើងនៅខេត្តសៀមរាប កាលពីខែឧសភា ២០០៩ បានបង្ហាញថា ពលករក្នុងវិស័យទេសចរណ៍ ជាពិសេសពលករនៅតាមសណ្ឋាគារ និងភោជនីយដ្ឋាន បានរងផលប៉ះពាល់ ដោយសារការថយចុះភ្ញៀវទេសចរ ។ បុគ្គលិកមួយចំនួន ត្រូវជំរុញឱ្យឈប់សំរាកដោយគ្មានបៀវត្សរ៍ ឬបញ្ឈប់ពីការងារជាបណ្តោះអាសន្ន ដូច្នេះ ក៏ត្រូវតែទៅរកការងារក្រៅផ្លូវការផ្សេងៗធ្វើ ដូចជា បើករថយន្តតាក់ស៊ី ឬបង្រៀនភាសាអង់គ្លេសក្រៅម៉ោង ជាដើម ។ ចលនាកំលាំងពលកម្មបែបនេះ បានធ្វើឱ្យអ្នកបើករថយន្តតាក់ស៊ី និងអ្នកលក់ដូរតូចតាច ត្រូវខំប្រឹងធ្វើការកាន់តែខ្លាំងក្នុងពេលតំរូវការកំពុងមានតិចនេះ ។

២ ខ្សែបន្ទាត់ភាពក្រីក្រនៅឆ្នាំ២០០៧ គឺប្រហែល ២០០៦រៀល ស្មើនឹង ០,៤៩ដុល្លារ ដោយប្រើអត្រាប្តូរប្រាក់ ៤០៦៣រៀល/ដុល្លារ (World Bank 2009) ។

៣ ទោះយ៉ាងណាក្តី គំរូតាងដែលជ្រើសរើសយកមកសិក្សាមានទំហំតូច ហើយមិនអាចយកមកតំណាងឱ្យក្រុមគ្រួសារទាំងអស់បានឡើយ ។

៤ តាំងពីឆ្នាំ២០០០ មក CDRI បានធ្វើអង្កេតរៀងរាល់ត្រីមាស លើពលករងាយរងគ្រោះចំនួន ១០ក្រុម ដែលរួមមាន: អ្នកធាក់ស៊ីក្លូ អ្នកលីសែង អ្នកលក់បន្លែតូចតាច អ្នករើសអេតចាយ អ្នករត់ម៉ូតូឌុប កម្មករសំណង់គ្មានជំនាញ កម្មករសំណង់មានជំនាញ អ្នកបំរើតុភោជនីយដ្ឋាន កម្មកររោងចក្រកាត់ដេរ និងអ្នកស៊ីឈ្នួលធ្វើស្រែ ។

តារាង ១: យុទ្ធសាស្ត្រផ្សេងៗរបស់ក្រុមគ្រួសារទទួលរងផលប៉ះពាល់ពីវិបត្តិ

| | ភាគរយនៃគ្រួសារ | |
|---|---|---|
| | ខែមីនា ២០០៨ | ខែឧសភា ២០០៩ |
| យុទ្ធសាស្ត្រសម្របខ្លួន [i] | 3.13 | 5.56 |
| យុទ្ធសាស្ត្រសកម្ម | 81.25 | 94.4 |
| យុទ្ធសាស្ត្របណ្តាញសង្គម [ii] | 2.5 | 13.8 |

i. ការផ្លាស់ប្តូរលំនាំចំណាយ

ii.ជំនួយពី មិត្តភក្តិ គ្រួសារ អង្គការមិនមែនរដ្ឋាភិបាល និង អង្គការរដ្ឋ ។

*ប្រភព: អង្កេតរបស់ CDRI លើ ៩០គ្រួសារ ក្នុង ៩ភូមិនៅជនបទ កាលពីខែមីនា ២០០៨ និងខែឧសភា ២០០៩ ។*

## យន្តការដោះស្រាយរបស់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ

ទិន្នន័យបានពីអង្កេតជាក្រុម បង្ហាញថា ប្រមាណ ៣៥% នៃក្រុមគ្រួសារដែលជ្រើសរើសធ្វើអង្កេតនៅឆ្នាំ២០០៨ និង ៤០% នៅឆ្នាំ២០០៩ បានទទួលរងការប៉ះទង្គិច ជាពិសេសការប៉ះទង្គិចខុសពីធម្មតា ។ ក្រុមគ្រួសារដែលរងផលប៉ះពាល់ រាយការណ៍ថា បានចំណាយជាមធ្យម ១៥៨ដុល្លារក្នុងមួយគ្រួសារ ដើម្បីទប់ទល់នឹងការប៉ះទង្គិចនេះ ក្នុងនេះ មានជាង ៨០% បានសម្របខ្លួនទ្រាំទ្រនឹងស្ថានភាព ដោយអនុវត្តយុទ្ធសាស្ត្រសកម្មរបស់គ្រួសារ តាមរយៈការប្រើប្រាស់ទ្រព្យរូបវ័ន្ត ហិរញ្ញវត្ថុ និងធនធានមនុស្ស ដូចជា ការដាក់បញ្ចូលសមាជិកគ្រួសារថែមទៀតទៅក្នុងកំលាំងពលកម្ម ការធ្វើការច្រើនម៉ោងជាងមុន លក់ទ្រព្យសម្បត្តិ ប្រើប្រាស់ប្រាក់សន្សំ ខ្ចីបុលគេ និងធ្វើចំណាកស្រុករកការងារ (តារាង ១) ។ ប៉ុន្តែមិនមានភស្តុតាងជាក់លាក់ណាមួយបង្ហាញថា យុទ្ធសាស្ត្របែបនេះ (ជាពិសេស ការលក់ដី ទ្រព្យសម្បត្តិក្រៅពីដី និងសត្វចិញ្ចឹម) ត្រូវបានប្រើប្រាស់ ដើម្បីឆ្លើយតបនឹងវិបត្តិឡើយ ។

កំរងទិន្នន័យមួយផ្សេងទៀត ដែលប្រមូលបានពីអង្កេតលើ ១០០៣ គ្រួសារ ក្នុង ៩ភូមិដដែលនេះ នៅខែមីនា និងខែកញ្ញា ២០០៨ បង្ហាញកាន់តែច្បាស់ពីយន្តការដោះស្រាយរបស់គ្រួសារនានា ក្នុងអំឡុងពេលម្ហូបអាហារឡើងថ្លៃ។ ដូចមានបង្ហាញក្នុងតារាង ២ ចំណាយលើទំនិញមិនមែនអាហារបានធ្លាក់ចុះ ២០% ពីខែមីនា ដល់ខែកញ្ញា ២០០៨[៥] ស្របពេលដែលចំណាយលើស្បៀងអាហារ ធ្លាក់ចុះតែ ១១% ។ ទោះបីទឹកប្រាក់ចំណាយលើម្ហូបអាហារ បានធ្លាក់ចុះក៏ពិតមែន ប៉ុន្តែភាគរយនៃចំណាយលើស្បៀងនៅក្នុងចំណាយសរុបប្រចាំគ្រួសារ នៅថេរដដែល ដែលបង្ហាញថា គ្រួសារទាំងនោះបានរឹតត្បិតចំណាយលើទំនិញមិនមែនអាហារ ដើម្បីយកមកទប់ចំណាយលើស្បៀងអាហារ ។

ទោះជាករណីសិក្សាផ្សេងៗគ្នា ផ្តល់ការសន្និដ្ឋានខុសៗគ្នាក៏ដោយ ក៏វាបានផ្តល់ខ្លឹមសាររួមមួយ គឺគ្រួសារនៅតាមតំបន់ជនបទកម្ពុជា ច្រើនតែអាចដោះស្រាយផលប៉ះពាល់នៃវិបត្តិដោយខ្លួនឯងបាន តាមរយៈការកែសំរួលសកម្មភាព និងការចំណាយរបស់ខ្លួន និងការប្រើប្រព័ន្ធសុវត្ថិភាពសហគមន៍មិនមែនផ្លូវការផ្សេងៗ ដែលតែងតែថយចុះខ្លះ ក្នុងគ្រាលំបាកលំបិន ។

## ការឆ្លើយតបជាគោលនយោបាយរបស់រដ្ឋាភិបាល

ដើម្បីឆ្លើយតបនឹងវិបត្តិសេដ្ឋកិច្ចសាកល រដ្ឋាភិបាល បានដាក់ចេញគោលនយោបាយមួយចំនួន រួមមាន:

៥ អតិផរណា ឡើងដល់ ២៦% នៅក្នុងខែឧសភា ២០០៨ ដែលជាអត្រាខ្ពស់បំផុត ក្នុង ៣ទសវត្សរ៍កន្លងមកនេះ ។

តារាង ២ : បញ្ចភាគចំណាយប្រើប្រាស់ពិតក្នុងមនុស្សម្នាក់ (ជាដុល្លារ)

| បញ្ចភាគ | ចំណាយសរុប | | អាហារ | | មិនមែនអាហារ | | ចំណាយសរុប | អាហារ | មិនមែនអាហារ |
|---|---|---|---|---|---|---|---|---|---|
| | មីនា-០៨ | កញ្ញា-០៨ | មីនា-០៨ | កញ្ញា-០៨ | មីនា-០៨ | កញ្ញា-០៨ | % ផ្លាស់ប្តូរ មីនា-កញ្ញា ០៨ | % ផ្លាស់ប្តូរ មីនា-កញ្ញា ០៨ | % ផ្លាស់ប្តូរ មីនា-កញ្ញា ០៨ |
| ១ (ទាបបំផុត) | 0.53 | 0.48 | 0.42 | 0.38 | 0.11 | 0.10 | -9.04 | -8.99 | -9.26 |
| ២ | 0.71 | 0.64 | 0.55 | 0.49 | 0.16 | 0.14 | -10.45 | -10.09 | -11.64 |
| ៣ | 0.85 | 0.76 | 0.65 | 0.58 | 0.20 | 0.18 | -10.41 | -10.88 | -8.86 |
| ៤ | 1.07 | 0.92 | 0.76 | 0.68 | 0.31 | 0.24 | -13.68 | -10.79 | -20.86 |
| ៥ (ខ្ពស់បំផុត) | 1.86 | 1.51 | 0.98 | 0.85 | 0.88 | 0.66 | -18.94 | -13.21 | -25.29 |
| សរុប | 0.97 | 0.86 | 0.67 | 0.60 | 0.33 | 0.26 | -11.38 | -11.16 | -20.06 |

*ប្រភព: ទិន្នន័យបានពីអង្កេតរបស់ CDRI ក្នុង ៩ភូមិ នៅខែមីនា និងខែកញ្ញា ២០០៨ និងខែកញ្ញា ២០០៩ ។*

- បង្កើនចំណាយថវិកា ដើម្បីប៉ះប៉ូវការធ្លាក់ចុះវិនិយោគឯកជន (ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច) ។
- ផ្អាកការយកពន្ធលើផលរបរប្រចាំខែ១% លើការចំណាយរបស់រោងចក្រកាត់ដេរ ។
- កាត់បន្ថយ ១០% លើប្រាក់កំរៃគ្រប់គ្រងការនាំចេញ និងបន្ទុកចំណាយផ្សេងៗ ។
- បង្កើតមូលនិធិអភិវឌ្ឍន៍ និងទ្រទ្រង់កសិកម្ម សម្រាប់វិស័យឯកជនជាពិសេសសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ដោយផ្តល់ឥណទានរយៈពេលខ្លី និងមានការប្រាក់ទាបទៅឱ្យកសិករ ដើម្បីបង្កើនផលិតភាពកសិកម្ម និងសន្តិសុខស្បៀង ។
- បង្កើតមូលនិធិពិសេសរបស់សម្តេចនាយករដ្ឋមន្ត្រី ដើម្បីផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លីដល់កម្មករដែលបាត់បង់ការងារ ។ រហូតមកដល់ខែកក្កដា ២០០៩ មានកម្មករត្រូវបានបញ្ឈប់ពីការងារ និងមិនមានការងារធ្វើ ចំនួន ៤០.១៤០នាក់ ដែលបានទទួលការបណ្តុះបណ្តាលបែបនេះផ្តល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងនោះ មាន ៣០.៧២០នាក់ (៧៦,៥%) បានទទួលការបណ្តុះបណ្តាលខាងកសិកម្ម និង ៩៤២០នាក់ទៀត (២៣,៥%) ខាងឧស្សាហកម្ម និងគ្រឿងយន្ត ។
- ចរចាជាមួយធនាគារពិភពលោក ទាក់ទងនឹងការផ្តល់ហិរញ្ញប្បទានប្រមាណ ១៣លានដុល្លារ សម្រាប់កម្មវិធីផ្សេងៗ ពាក់ព័ន្ធនឹងប្រព័ន្ធសុវត្ថិភាពសង្គម ។

ទោះមានចំណាត់ការដូចខាងលើក្តី ក៏មានការទទួលស្គាល់ជាទូទៅថា វិធានការទាំងនេះ ទំនងមិនអាចជះឥទ្ធិពលទៅដល់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះនៅតាមតំបន់ជនបទ ឬទីក្រុងឡើយ ។

## អនុសាសន៍សម្រាប់រយៈពេលខ្លី និងមធ្យម

តួនាទីដែលអ្នកកសាងគោលនយោបាយ ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលទទួលអនុវត្ត អាចកំណត់បាននូវផលប៉ះពាល់ពិតប្រាកដនៃវិបត្តិទៅលើកំណើន និងភាពក្រីក្រនៅកម្ពុជា ។ ផលប៉ះពាល់ទំនងមានលក្ខណៈធ្ងន់ធ្ងរលើក្រុមប្រជាជនក្រីក្រ និងជនងាយរងគ្រោះ ។ ដោយសារស្ថានភាពសេដ្ឋកិច្ច និងឋានៈសង្គមរបស់ខ្លួន ពួកគេទំនងត្រូវរងគ្រោះមុនគេពីការប៉ះទង្គិច ដូចជា ត្រូវបាត់បង់ការងារ និងចំណូល ឬថយចុះអំណាចទិញ ដោយសារទំនិញឡើងថ្លៃ (Jalilian *et al*. 2009) ។ ដោយសារជនក្រីក្រ និងជនងាយរងគ្រោះ មានចំនួនច្រើននៅកម្ពុជា ដូច្នេះ ត្រូវផ្តល់សារៈសំខាន់ដល់គោលនយោបាយសម្រាប់ជួយដល់ពួកគេ ។ នៅក្នុងប្រទេសមួយចំនួន ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ តែងទទួលបានជំនួយ (ដោយផ្ទាល់ ឬដោយប្រយោល) ពីរដ្ឋាភិបាល ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងពេលជួបការលំបាកខ្លាំង ។ ជំនួយទាំងនោះ អាចជាសម្ភារៈ ឬឧបត្ថម្ភធនជួយចេញខាតលើថ្លៃទំនិញ របបអាហារ ប័ណ្ណអាហារ ស្បៀងពលកម្ម ការផ្តល់អាហារតាមសាលារៀន ជាដើម ។

វិបត្តិ មិនគ្រាន់តែនាំឱ្យមានបំរែបំរួលខ្លាំងក្នុងកម្រិតជីវភាពប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែកង្វះខាតមធ្យោបាយសម្រាប់ទប់ទល់នឹងហានិភ័យ ធ្វើឱ្យភាពក្រីក្រតោកយ៉ាកនៅអូសបន្លាយយូរអង្វែង ។ ដូច្នេះ យុទ្ធសាស្ត្រសម្រាប់ដោះស្រាយនៅមុនពេល និងក្រោយពេលមានវិបត្តិ ដូចជា ការជំរុញឥណទានប្រាក់សន្សំទុកការពារខ្លួន ព្រមទាំងប្រព័ន្ធសុវត្ថិភាពសង្គម ដែលអាចជឿទុកចិត្តបាន អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារប្រជាជនក្រីក្រ និងជនងាយរងគ្រោះ ។ ម្យ៉ាងវិញទៀត គួរយកចិត្តទុកដាក់ពង្រឹងប្រព័ន្ធធានារ៉ាប់រងសង្គមក្រៅផ្លូវការ ពីព្រោះក្រុមប្រជាជនក្រីក្រ និងជនងាយរងគ្រោះ អាចប្រើប្រាស់មូលធនសង្គមនៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីការពារចំណាយប្រើប្រាស់របស់ខ្លួន នៅពេលប្រាក់ចំណូលមានការឡើងចុះ ។

## សេចក្តីសន្និដ្ឋាន

វិបត្តិសេដ្ឋកិច្ចសាកល មានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជាជនក្រីក្រ និងជនងាយរងគ្រោះ ទាំងនៅជនបទ និងនៅទីក្រុង ។ វិបត្តិហាក់ដូចបានប៉ះពាល់ជនក្រីក្រភ្លាមៗតាមរយៈស្ថានភាពការងារ និងចំនួនប្រាក់ផ្ញើមកផ្ទះ ហើយការប៉ះពាល់នេះ ទំនងជាកាន់តែធ្ងន់ធ្ងរថែមទៀតក្នុងរយៈពេលមធ្យម ដោយសារតែភាពអន់ខ្សោយនៃយុទ្ធសាស្ត្រសម្រាប់ដោះស្រាយ នៅមុនពេល និងក្រោយពេលមានវិបត្តិ ប្រព័ន្ធធានារ៉ាប់រងសង្គមក្រៅផ្លូវការ ក៏ដូចជា កង្វះការឆ្លើយតបរបស់វិស័យសាធារណៈ ។

រដ្ឋាភិបាល គួរតែអាចលើកកំពស់ប្រព័ន្ធធានារ៉ាប់រងសម្រាប់ជនក្រីក្រ តាមរយៈការបង្កើតក្របខ័ណ្ឌច្បាប់សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការជួយពង្រឹងប្រព័ន្ធសុវត្ថិភាពសង្គមឱ្យមានលក្ខណៈអាចជឿទុកចិត្តបាន ។

## ប្រភព:

Bauer, Armin, Rana Hasan, Rohoda Magsombol & Guanghua Wan (2008), *The World Bank's New Poverty Data: Implications for the Asian Development Bank*, ADB Sustainable Development Working Paper Series (Manila: ADB)

Jalilian, Hossein, Chan Sophal, Glenda Reyes, Siang Chan Hang, Phann Dalis & Pon Dorina (2009), *The Global Financial Crisis and Developing Countries: Cambodia* (Phnom Penh: CDRI)

Tong Kimsun, Siang Chanhang & Hem Socheth with Phann Dalis, Hem Metta & Pon Dorina (forthcoming), *Trends in Living Standards of 90 Rural Households in Poverty Dynamics Study Villages* (Phnom Penh: CDRI)

Tong Kimsun, Khieng Sothy & Phann Dalis with Hem Metta & Pon Dorina (2009), *Vulnerable Workers Survey in Phnom Penh, Kandal, Kompong Speu, Siem Reap and Battambang*. (Phnom Penh: CDRI)

World Bank (2009), *Poverty Estimates for Cambodia 2007: Report to the EAS Country Units of the World Bank Washington DC*